**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

ព្រះរាជាណាចក្រកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ, ថ្ងៃទី ០4 ខែសីហា ឆ្នាំ ១៩៩៧

**លេខ: 33 សណ.គក**

# សេចក្តីណែនាំ

## ស្តីពី

## តួនាទី ភារកិច្ច សិទ្ធ រចនាសម្ព័ន្ធ និង របៀបរបប
## ធ្វើការងាររបស់គណៈកម្មាធិការគណបក្សឃុំ–សង្កាត់

***************

–យោងមាត្រាទី ១៤ ជំពូក V នៃលក្ខន្តិកៈគណបក្សអនុម័តដោយមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសគណបក្សប្រជាជនកម្ពុជា ថ្ងៃទី ២៤–២៧ ខែ មករា ឆ្នាំ ១៩៩៧ ។

–យោងស្មារតីអង្គប្រជុំគណៈប្រចាំការគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល នាថ្ងៃទី ៣០ ៧ . ១៩៩៧ និង មតិឯកភាពរបស់សម្តេចប្រធាន សម្តេចអនុប្រធាន និង សម្តេចប្រធានកិត្តិយសគណបក្ស .

**គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល** ធ្វើការណែនាំដល់បណ្តាខេត្ត–ក្រុង អំពីរាល់ការងាររបស់គណៈកម្មាធិការគណបក្សឃុំ– សង្កាត់ ដូចខាងក្រោម :–

I- **អំពីតួនាទី** :

គណៈកម្មាធិការគណបក្សឃុំ– សង្កាត់ គឺជាអង្គការចាត់តាំងមូលដ្ឋានរបស់គណបក្ស ស្ថិតក្រោមការដឹកនាំណែនាំផ្ទាល់របស់គណៈកម្មាធិការគណបក្សស្រុក–ខ័ណ្ឌ ។ គណៈកម្មាធិការគណបក្សឃុំ–សង្កាត់មានតួនាទី :–

– ក្តាប់ជាប់នូវកម្មវិធីនយោបាយរបស់គណបក្ស ដើម្បីចាត់តាំងអនុវត្តអោយបានស្របតាមសភាពការណ៍ជាក់ស្តែងនៅមូលដ្ឋាន ។

–ដឹកនាំការងារគណបក្ស អំពីការងារនយោបាយ សតិអារម្មណ៍ និង ចាត់តាំងក្នុងក្របខ័ណ្ឌមូលដ្ឋានរបស់ខ្លួន ។

– ផ្សារភ្ជាប់ជិតស្និតជាមួយមហាជន ប្រជាជននៅមូលដ្ឋាន ខិតខំបំផុសមហាជនចូលរួមកសាងពង្រឹងរដ្ឋអំណាច និង កែលំអជីវភាពរស់នៅ ។

– ការពារឥទ្ធិពល និង ប្រជាប្រិយភាពរបស់គណបក្ស ខិតខំប្រមូលកំលាំងមហាជនច្រើនកុះករ អោយគាំទ្រគណបក្សប្រជាជនកម្ពុជា ។

II- **អំពីភារកិច្ច** :

ក្នុងសភាពការណ៍បច្ចុប្បន្ននេះ គណៈកម្មាធិការគណបក្សឃុំ– សង្កាត់ មានភារកិច្ចដូចខាងក្រោម :–

១– ក្តាប់ជាប់កម្មវិធីនយោបាយ លក្ខន្តិកៈ គោលការណ៍នានារបស់គណបក្ស និង សេចក្តីសំរេចផ្សេងៗ របស់គណបក្សថ្នាក់លើ កសាងទិសដៅ និង ផែនការអនុវត្តអោយបានសមស្រប និងសភាពការណ៍ជាក់ស្តែងនៅមូលដ្ឋាន ហើយចាត់តាំង និង បំផុសចលនាសមាជិកគណបក្ស សកម្មចូលរួមអនុវត្តរាល់ទិសដៅទាំងនោះអោយបានសំរេច ។

២– យកចិត្តទុកដាក់អប់រំសមាជិកគណបក្ស ប្រជាជន មហាជន អោយបានយល់ជ្រួតជ្រាបច្បាស់អំពីកម្មវិធីនយោបាយ លក្ខន្តិកៈ គោលការណ៍ និង សេចក្តីសំរេចនានារបស់គណបក្ស និង ច្បាប់របស់រដ្ឋ អំពីសភាពការណ៍ និង សមិទ្ធិផលនានារបស់ជាតិ ដើម្បីធ្វើអោយសមាជិកគណបក្ស ប្រជាជន មហាជនមានស្មារតីភ្ញាក់រលឹកខ្ពស់ និង សមានចិត្តគាំទ្រគណបក្សប្រជាជនយ៉ាងសកម្ម ហើយចូលរួមគ្រប់សកម្មភាពរបស់គណបក្សក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ។

៣– បង្កើនសាមគ្គីភាព ឯកភាព ក្នុងជួរសមាជិកគណបក្ស ផ្សារភ្ជាប់ជិតស្និតជាមួយប្រជាជន មហាជន និង មានទំនាក់ទំនង សហការល្អជាមួយរដ្ឋអំណាច អង្គការសង្គម អង្គការក្រៅរដ្ឋាភិបាល អង្គភាពផលិតកម្ម អង្គភាពជំនាញ ដែលបោះទីតាំងនៅមូលដ្ឋានរបស់ខ្លួន ដើម្បីជំរុញការអភិវឌ្ឍន៍មូលដ្ឋានភូមិ ឃុំសំដៅកែលំអជីវភាពរស់នៅទាំងខាងស្មារតី និង សំភារៈ ។

៤– បែងចែកភារកិច្ចទទួលខុសត្រូវ និង ត្រួតពិនិត្យការងាររបស់សមាជិកនៃគណៈកម្មាធិការគណបក្ស ។ គ្រប់គ្រងសមាជិកគណបក្សអោយបានល្អ អនុវត្តភារកិច្ច លើកសរសើរ និង ដាក់វិន័យចំពោះសមាជិកគណបក្ស ។ យកចិត្តទុកដាក់ជំរុញការងារពង្រីកសមាជិកថ្មី និង ការងារពង្រឹងគណបក្ស អនុវត្តរបបប្រជុំជីវភាពគណបក្សទៀងទាត់ ព្រមទាំងបំផុសស្មារតីភ្ញាក់រលឹកបង់ភាគទានប្រចាំខែស្របតាមការកំណត់របស់លក្ខន្តិកៈ ។ ខិតខំចលនាទាក់ទាញកំលាំងនៃគ្រប់មុខសញ្ញា ដែលនៅសល់មិនទាន់ចូលជាសមាជិកគណបក្សអោយក្លាយជាកំលាំងគាំទ្រគណបក្ស ។

៥– លើកកំពស់ស្មារតីប្រុងប្រយ័ត្នការពារមន្ត្រីគណបក្សដែលស្ថិតក្នុងជួររដ្ឋអំណាច រក្សាការសម្ងាត់របស់គណបក្ស ទប់ស្កាត់អោយបានដាច់ខាតនូវការជ្រៀតចូលនៃសមាសភាពនិកាសនិយម ដើម្បីបំផ្លិចបំផ្លាញគណបក្ស ។ បកអាក្រាតទាន់ពេលវេលានូវរាល់ល្បិចកល ឬ ការឃោសនាមួលបង្កាច់ ដែលធ្វើអោយខូចកិត្យានុភាពរបស់គណបក្ស ។

៦- លើកកំពស់ស្មារតីម្ចាស់ការក្នុងការគ្រប់គ្រង និង ថែរក្សាទ្រព្យសម្បត្តិរបស់គណបក្សនៅថ្នាក់មូលដ្ឋានរបស់ខ្លួនអោយបានម៉ត់ចត់ និង អនុវត្តគោលការណ៍សន្សំសំចៃ មិនខ្ជះខ្ជាយ ហើយសមាជិកគណបក្សត្រូវប្រកាន់ខ្ជាប់នូវសីលធម៌ថ្លៃថ្នូរ អត្តចរិតស្លូតបូត ទំនាក់ទំនងល្អជាមួយប្រជាជន មហាជន តែម៉ឺងម៉ាត់ក្នុងការបំពេញភារកិច្ចដែលគណបក្សប្រគល់អោយ ។

III - **អំពីសិទ្ធិ** :

គណៈកម្មាធិការគណបក្សឃុំ-សង្កាត់ មានសិទ្ធដូចខាងក្រោម :-

**១- អំពីសិទ្ធិអំណាច :**

-សំរេចយល់ព្រមទទួលស្គាល់សមាជិកថ្មី សំរេចបង្កើតអនុសាខាគណបក្ស និង ក្រុមបក្ស ដោយមានការយល់ព្រមយ៉ាងតិចបំផុត ២ ភាគ ៣ នៃសមាជិកក្នុងគណៈកម្មាធិការគណបក្ស ។

-អញ្ជើញបណ្តាសមាជិកគណៈកម្មាធិការគណបក្ស ប្រធាន អនុប្រធានសាខាគណបក្ស ប្រធាន អនុប្រធានក្រុមបក្ស និង សមាជិកគណបក្សទាំងអស់ក្នុងមូលដ្ឋានខ្លួន ព្រមទាំងប្រជាជន មហាជន ដែលមានសមានចិត្តចំពោះគណបក្សប្រជាជន ចូលរួមគ្រប់ការប្រជុំនានាតាមការកំណត់ ។

-ក្រើនរំលឹកដាស់តឿន និង ណែនាំការងារគណបក្សដល់សាខា អនុសាខាគណបក្ស និង ក្រុមបក្ស ។

**២- អំពីសិទ្ធិស្នើយោបល់** :

គណៈកម្មាធិការគណបក្សឃុំ-សង្កាត់ ត្រូវលើសំណើការងារមួយចំនួនទៅគណៈកម្មាធិការគណបក្សស្រុក-ខ័ណ្ឌ ដើម្បីសុំសេចក្តីសំរេចរួមមាន :-

-លើកសំណើស្តីពីការបង្កើត និង តែងតាំងសមាសភាពដឹកនាំសាខា គណៈកម្មាធិការសាខា និង លើកសរសើរ ដាក់វិន័យចំពោះសមាជិកគណបក្ស ។

-លើកសំណើអំពីការងារគណបក្សដែលនៅមានភាពទុញទាល់ មិនទាន់ឯកភាពគ្នាក្នុងគណៈកម្មាធិការគណបក្ស ។

-សំណូមពរផ្សេងៗរបស់សាខា គណៈកម្មាធិការសាខា ក្រុមបក្ស ឬ សមាជិកគណបក្សព្រមទាំងសំណូមពររបស់ មហាជន ប្រជាជន ដែលគណៈកម្មាធិការគណបក្សឃុំ-សង្កាត់មិនអាចដោះស្រាយបាន ។

-បើមានការសុំចូលជាសមាជិកគណបក្សក្នុងករណីពិសេស ត្រូវសុំយោបល់សំរេចពីគណបក្សថ្នាក់លើ ។

IV- **រចនាសម្ព័ន្ធ និង ការបែងចែកភារកិច្ចការងាររបស់គណៈកម្មាធិការគណបក្សឃុំ សង្កាត់** :

បរិមាណគណៈកម្មាធិការគណបក្សឃុំ-សង្កាត់ អាចមានចំនួនតិច ឬ ច្រើនដោយយោលទៅលើបរិមាណសមាជិកគណបក្សក្នុងមូលដ្ឋាននិមួយៗ ។

បើបរិមាណសមាជិកគណៈកម្មាធិការគណបក្សមាន ៥ រូប ត្រូវបែងចែកការងារអោយទទួលដូចខាងក្រោម :-

១- ប្រធាន ទទួលដឹកនាំរួម

២- អនុប្រធាន ទទួលការងារចាត់តាំង និង កសាងគណបក្ស

៣- អនុប្រធាន ទទួលការងារឃោសនាអប់រំ និង ចលនាមហាជន

៤- សមាជិក ទទួលការងារហិរញ្ញវត្ថុ និង ជីវភាព

៥- សមាជិក ទទួលការងារត្រួតពិនិត្យ

ចំពោះឃុំ- សង្កាត់ដែលមានសមាជិកគណបក្សច្រើន បើមានបរិមាណសមាជិកគណៈកម្មាធិការគណបក្សពី ៦ ទៅ ៩ រូប គឺត្រូវពិនិត្យប្រធាន ឬ អនុប្រធានអង្គភាព ឬ មូលដ្ឋានណាសំខាន់ ដែលជាប្រធានសាខាគណបក្សដើម្បីបញ្ចូលជាសមាជិកគណៈកម្មាធិការគណបក្សអោយស្របនឹងសភាពជាក់ស្តែងរបស់មូលដ្ឋាន ដូចជាប្រធានសាខាគណបក្សភូមិ , នាយក ឬ នាយករងសាលារៀន , មន្ទីរពេទ្យ ,ប្រធាន ឬ អនុប្រធានអង្គភាពអាជីវកម្ម , ផលិតកម្ម ។ល។

គណៈកម្មាធិការគណបក្សឃុំ- សង្កាត់ ត្រូវបង្កើតអោយមានចំនួនសមាជិកអចិន្ត្រៃយ៍ស្មើនឹងមួយភាគបីនៃសមាជិកគណៈកម្មាធិការគណបក្សទាំងអស់ ដើម្បីដឹកនាំការងារគណបក្សគ្រប់ផ្នែកជាប្រចាំ ។

ចំពោះមុខគណៈកម្មាធិការគណបក្សស្រុក- ខ័ណ្ឌ ត្រូវចង្អុលតែងតាំងសមាជិកគណបក្ស ដែលជាមេឃុំ ចៅសង្កាត់អោយធ្វើជាប្រធានគណៈកម្មាធិការគណបក្ស ។ ប្រសិនបើមេឃុំ ចៅសង្កាត់នោះមិនមែនជាសមាជិកគណបក្សប្រជាជនកម្ពុជាទេ ឬ ជាសមាជិកគណបក្សប្រជាជនកម្ពុជាដែរ តែខ្វះសមត្ថភាពដឹកនាំ ត្រូវចង្អុលតែងតាំងសមាជិកគណបក្សដែលជាមន្ត្រីនៅថ្នាក់ឃុំ- សង្កាត់ និង មានលក្ខណៈសម្បត្តិគ្រប់គ្រាន់អោយធ្វើជាប្រធានគណៈកម្មាធិការគណបក្សឃុំ- សង្កាត់ ។

V- **អំពីរបៀបរបបធ្វើការងារ**:

-គណៈកម្មាធិការគណបក្សឃុំ- សង្កាត់ ប្រជុំជីវភាពមួយខែម្តង ពេលចាំបាច់ត្រូវប្រជុំវិសាមញ្ញ។

-មហាសន្និបាតត្រូវដំណើរការមួយឆ្នាំម្តង ដើម្បីត្រួតពិនិត្យការដឹកនាំរបស់គណបក្សក្នុងឆ្នាំកន្លងមក និង ពិភាក្សាអនុម័តទិសដៅការងារសំរាប់ឆ្នាំបន្ទាប់ លើការងារនយោបាយ សតិអារម្មណ៍ ចាត់តាំង ត្រួតពិនិត្យ ហិរញ្ញវត្ថុជីវភាព និង បោះឆ្នោតជ្រើសតាំងគណៈកម្មាធិការគណបក្សឃុំ- សង្កាត់ថ្មី ។

-គណៈកម្មាធិការគណបក្សឃុំ- សង្កាត់ ត្រូវចាត់តាំងសមាជិកអោយទទួលខុសត្រូវចុះជួយពង្រឹងគ្រប់សាខាគណបក្សចំណុះអោយបានជាប់ជាប្រចាំ ដើម្បីអោយសាខាគណបក្សទាំងនោះមានលទ្ធភាព និង សមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាពនៅមូលដ្ឋាន ។

-ក្រៅពីការប្រជុំជីវភាពប្រចាំខែ គណៈកម្មាធិការគណបក្សឃុំ- សង្កាត់ ត្រូវកំណត់ពេលវេលា

មួយដង ឬ ពីរដង ដើម្បីរៀនសូត្រអោយជ្រួតជ្រាបអំពីសភាពការណ៍ និង ភារកិច្ចរបស់គណបក្ស ព្រមទាំងសេចក្ដីសំរេចចិត្តនានារបស់គណបក្សថ្នាក់លើ ។

– គណៈកម្មាធិការគណបក្សឃុំ– សង្កាត់ ត្រូវអនុវត្តអោយបានទៀងទាត់នូវរបបរាយការណ៍ប្រចាំខែអំពីសកម្មភាពការងាររបស់គណបក្សនៅថ្នាក់ខ្លួន ជូនគណៈកម្មាធិការគណបក្សស្រុក ខ័ណ្ឌ ។

– រាល់សេចក្ដីសំរេចរបស់គណៈកម្មាធិការគណបក្សឃុំ– សង្កាត់ ត្រូវចុះហត្ថលេខាដោយប្រធាន អនុប្រធាន និង ប្រចាំការរបស់គណៈកម្មាធិការគណបក្សឃុំ– សង្កាត់ ។ គណៈកម្មាធិការគណបក្សខេត្ត– ក្រុង ត្រូវធ្វើទំនាក់ទំនងជាមួយក្រសួងមហាផ្ទៃតាមបែបបទនៃច្បាប់ ដើម្បីដោះស្រាយត្រាជូន គណៈកម្មាធិការគណបក្សឃុំ– សង្កាត់ ។

ផ្អែកតាមសេចក្ដីណែនាំខាងលើនេះ គណៈកម្មាធិការគណបក្សខេត្ត– ក្រុង មានភារៈធ្វើការណែនាំអនុវត្ត និង ចុះជួយរៀបចំជាក់ស្ដែងក្នុងការបង្កើតគណៈកម្មាធិការគណបក្សឃុំ– សង្កាត់ អោយស្របនឹងសភាពការណ៍ជាក់ស្ដែងរបស់មូលដ្ឋាន ។

គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រគល់ភារកិច្ចអោយគណៈចាត់តាំងគណៈកម្មាធិការកណ្ដាល ត្រួតពិនិត្យអនុវត្តសេចក្ដីណែនាំនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

សេចក្ដីណែនាំដែលមានពីមុន ហើយផ្ទុយនឹងសេចក្ដីណែនាំនេះ ត្រូវទុកជានិរាករណ៍ ។

ជ- គណៈអចិន្ត្រៃយ៍

សាយ ឈុំ

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

លេខ : ៧៩ សណ.គក

ភ្នំពេញ , ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០២

# សេចក្តីណែនាំបន្ថែម
# ស្តីពី
# ការរៀបចំរចនាសម្ព័ន្ធ អង្គការចាត់តាំង និង
# របៀបរបបធ្វើការងាររបស់គណៈកម្មាធិការគណបក្សឃុំ—សង្កាត់

- យោងសេចក្តីណែនាំលេខ ៣៣ សណ.គក ចុះថ្ងៃទី ៤ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់គណៈកម្មាធិការគណបក្សឃុំ-សង្កាត់

- ផ្អែកតាមសំណូមពរនៃភារកិច្ចនយោបាយរបស់គណបក្សនាតំណាក់កាលបច្ចុប្បន្ន

- យោងមតិឯកភាពរបស់ **គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល**

**គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល** ណែនាំបន្ថែមស្តីពីការរៀបចំរចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការងាររបស់គណៈកម្មាធិការគណបក្សឃុំ-សង្កាត់ ដូចខាងក្រោម ៖

## I — អំពីរចនាសម្ព័ន្ធ អង្គការចាត់តាំង :

**១** - បរិមាណសមាជិកគណៈកម្មាធិការគណបក្សឃុំ-សង្កាត់ ដែលរួមមានប្រធាន អនុប្រធាន សមាជិកអចិន្ត្រៃយ៍និងសមាជិក ត្រូវបានកំណត់អោយមានចំនួនតិចឬច្រើន ដោយផ្អែកលើបរិមាណសាខាចំណុះនិងសមាជិកគណបក្សនៅក្នុងឃុំ-សង្កាត់នីមួយៗ តាមប្រភេទឃុំ-សង្កាត់ធំ ឬមធ្យម និងតូច ដូចខាងក្រោម ÷

- ឃុំ-សង្កាត់ធំ (ដែលមានសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ពី ៩ ដល់ ១១ រូប) គណៈកម្មាធិការគណបក្សមានចំនួន ២១ រូបចុះ ។

- ឃុំ-សង្កាត់ មធ្យម និងតូច (ដែលមានសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ពី ៥ ដល់ ៧ រូប) គណៈកម្មាធិការគណបក្សមានចំនួន ១៥ រូបចុះ ។

- ចំពោះគណៈកម្មាធិការគណបក្សឃុំ-សង្កាត់ ដែលមានសាខាចំណុះចំនួន ២០ឡើងទៅ អាចរៀបចំអោយមានបរិមាណសមាជិកចំនួន ២៥ រូបចុះ ។

- រៀបចំអោយមានសមាជិកាគណៈកម្មាធិការគណបក្សឃុំ-សង្កាត់ ជានារីចំនួន ២ រូបឡើងទៅ ។

២ - កំណត់បន្ថែមសមាសភាពគណៈកម្មាធិការគណបក្សឃុំ-សង្កាត់ រួមមានសមាជិកគណបក្សជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ជាប្រធានប៉ុស្តិ៍រដ្ឋបាល ដែលមានលក្ខណសម្បត្តិល្អ មានគោលជំហរនយោបាយរឹងមាំ មានប្រជាប្រិយភាពក្នុង មហាជន ប្រជាជន មានសមត្ថភាព និងស្មារតីសកម្មអនុវត្តភារកិច្ចការងារគណបក្សដែលបានប្រគល់ជូន ។

៣ - គណៈកម្មាធិការគណបក្សឃុំ-សង្កាត់ ត្រូវបែងចែកភារកិច្ចដល់សមាជិកម្នាក់ៗក្នុងគណៈកម្មាធិការគណបក្ស និងគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស អោយទទួលបន្ទុកចង្កោមការងារគណបក្ស ឬផ្នែកការងារនីមួយៗ និងទទួលបន្ទុកដឹកនាំកសាងពង្រឹងបណ្តាសាខាចំណុះនៅតាមភូមិ សាលារៀន មណ្ឌលសុខភាព អង្គភាព អាជីវកម្ម ផលិតកម្មនានា ។

៤ - ចាត់តាំងមន្ត្រីប្រចាំការស្នាក់ការគណបក្សឃុំ-សង្កាត់ ដើម្បីទទួលបន្ទុកការងារគ្រប់គ្រងសមាជិក ទំនាក់ទំនងជាមួយមហាជន ប្រជាជន រៀបចំចាត់តាំងការប្រជុំជីវភាព និងសកម្មភាពគណបក្សនៅមូលដ្ឋាន ។

## II — **នីតិវិធីរបៀបរបបធ្វើការងារ** :

១ - គណៈកម្មាធិការគណបក្សឃុំ-សង្កាត់ មានភារកិច្ចដឹកនាំណែនាំដល់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ របស់គណបក្ស ដែលរួមមាន មេឃុំ-ចៅសង្កាត់ ជំទប់-ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ជំរុញការអភិវឌ្ឍន៍ឃុំ-សង្កាត់ ស្របតាមកម្មវិធីនយោបាយរបស់គណបក្ស និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

២ - សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ របស់គណបក្ស មានភារៈទទួលខុសត្រូវផ្ទាល់ចំពោះមុខគណៈកម្មាធិការគណបក្សឃុំ-សង្កាត់ ក្នុងការដឹកនាំចាត់តាំងប្រមូលកំលាំងចូលរួមអនុវត្តអោយបានជោគជ័យនូវកម្មវិធីនយោបាយរបស់គណបក្សក្នុងការអភិវឌ្ឍន៍ឃុំ-សង្កាត់ ដើម្បីថែរក្សា និងពង្រឹងប្រជាប្រិយភាពរបស់គណបក្ស បង្កើននូវជំនឿទុកចិត្ត និងសមានចិត្តគាំទ្ររបស់មហាជន ប្រជាជនចំពោះគណបក្ស ។

៣ - សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់របស់គណបក្ស ត្រូវលើកសំណើប្រជុំរាយការណ៍ជូនគណៈកម្មាធិការគណបក្ស នូវបញ្ហាជាគោលការណ៍ចំបងនានាក្នុងការងារសំខាន់ៗ និងកម្មវិធីអភិវឌ្ឍន៍ឃុំ-សង្កាត់ ដើម្បីពិភាក្សាឯកភាពគ្នា កំណត់គោលជំហររបស់គណបក្សជាមុន សំរាប់ការពិភាក្សាអនុម័តនៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ក្នុងករណីមិនទាន់មានមតិឯកភាពភាគច្រើន ឬយល់ឃើញថាចាំបាច់ ប្រធានគណៈកម្មាធិការគណបក្សឃុំ-សង្កាត់ ត្រូវរាយការណ៍សុំគោលការណ៍ណែនាំបន្ថែមពីគណបក្សថ្នាក់លើ ។

## III — **វិធានការចាត់តាំងអនុវត្ត** :

១ - គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ត្រូវផ្អែកលើសេចក្តីណែនាំលេខ ៣៣ សណ.គក ចុះថ្ងៃទី ៤.៨ ១៩៩៧ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់គណៈកម្មាធិការគណបក្សឃុំ-សង្កាត់ និងសេចក្តីណែនាំបន្ថែមនេះ ដើម្បីធ្វើការណែនាំអនុវត្ត និងចាត់តាំងកំលាំងចុះជួយរៀបចំកសាងពង្រឹងគណៈកម្មាធិ

ការគណបក្សឃុំ-សង្កាត់ អោយស្របតាមសភាពការណ៍ជាក់ស្តែងបច្ចុប្បន្ន ដែលមានស្ថានភាពចំរុះពហុបក្សនៅមូលដ្ឋាន ដោយត្រូវអនុវត្តអោយបានសំរេចរួចរាល់នៅមុនដំណាច់ឆ្នាំ ២០០២ នេះ ។

២ - គណៈកម្មាធិការគណបក្សឃុំ-សង្កាត់ ត្រូវផ្អែកលើគោលការណ៍ណែនាំជាក់ស្តែង របស់គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ស្រុក-ខណ្ឌ ដើម្បីលើកសំណើអំពីការរៀបចំសមាសភាពគណៈកម្មាធិការគណបក្សឃុំ-សង្កាត់ ដោយមានការយល់ព្រមយ៉ាងតិច ២ ភាគ ៣ នៃសមាជិកក្នុងគណៈកម្មាធិការគណបក្ស ។

៣ - គណៈកម្មាធិការគណបក្សស្រុក-ខណ្ឌ ពិនិត្យសំរេចអំពីការរៀបចំសមាសភាពគណៈកម្មាធិការគណបក្សឃុំ-សង្កាត់ ចាប់ពីថ្នាក់អនុប្រធានចុះ ស្របតាមគោលការណ៍ណែនាំរបស់គណបក្សថ្នាក់លើ ។

៤ - គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ពិនិត្យសំរេចអំពីការរៀបចំប្រធានគណៈកម្មាធិការគណបក្សឃុំសង្កាត់ ។

៥ - គណៈកម្មាធិការគណបក្សខេត្ត-ក្រុង ត្រូវពិនិត្យសំរេចអំពីការរៀបចំកែសំរួលរចនាសម្ព័ន្ធគណៈកម្មាធិការគណបក្សឃុំ-សង្កាត់ តាមគោលការណ៍ណែនាំខាងលើនេះ អោយស្របតាមសភាពការណ៍ជាក់ស្តែងនៅមូលដ្ឋានរបស់ខ្លួន ដោយត្រូវរក្សាអោយបាននូវសាមគ្គីភាព ឯកភាពផ្ទៃក្នុង និងលើកកំពស់ស្មារតីទទួលខុសត្រូវក្នុងការពុះពារអនុវត្តសំរេចភារកិច្ចការងារគណបក្សដែលបានប្រគល់ជូន ។

៦ - គណៈចាត់តាំងគណៈកម្មាធិការកណ្តាល ខុទ្ទកាល័យគណៈកម្មាធិការកណ្តាល និងបណ្តាស្ថាប័នគណបក្សដែលពាក់ព័ន្ធ ត្រូវត្រួតពិនិត្យការអនុវត្តន៍សេចក្តីណែនាំនេះអោយមានប្រសិទ្ធិភាព ។

ជ- គណៈអចិន្ត្រៃយ៍

សាយ ឈុំ

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខ: ០០៥/១៧ សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ,ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧

# សេចក្តីណែនាំ
# ស្តីពី
# ការរៀបចំបំពេញបន្ថែមសមាសភាព
# គណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្សឃុំ សង្កាត់

**យោង :** - សេចក្តីណែនាំលេខៈ ៣៣ សណ.គក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់គណៈកម្មាធិការគណបក្សឃុំ សង្កាត់

- សេចក្តីណែនាំបន្ថែមលេខៈ ៧៩ សណ.គក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីការរៀបចំរចនាសម្ព័ន្ធ អង្គការចាត់តាំង និងរបៀបរបបធ្វើការងាររបស់គណៈកម្មាធិការគណបក្សឃុំ សង្កាត់
- សំណូមពរនៃភារកិច្ចនយោបាយរបស់គណបក្សនាដំណាក់កាលបច្ចុប្បន្ន
- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៧

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល** ណែនាំអំពីការរៀបចំបំពេញបន្ថែមសមាសភាពគណៈអចិន្ត្រៃយ៍ និងគណៈកម្មាធិការគណបក្សនៃឃុំ សង្កាត់ ដែលមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ជាសមាជិកបក្សថ្មីមកពីគណបក្សផ្សេងដែលសុំចូលរួមជីវភាពជាមួយគណបក្សប្រជាជនកម្ពុជា ដូចខាងក្រោម ៖

១-ទទ្ទឹមនឹងបន្តអនុវត្តតាមរចនាសម្ព័ន្ធចាស់ ដែលបានកំណត់ គណៈកម្មាធិការគណបក្សឃុំ សង្កាត់នីមួយៗ អាចពង្រីកបន្ថែមរចនាសម្ព័ន្ធគណបក្សថ្នាក់ខ្លួន នៅក្នុងជួរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ជាសមាជិកបក្សថ្មី មកពីគណបក្សផ្សេងដែលសុំចូលរួមជីវភាពជាមួយគណបក្សប្រជាជនកម្ពុជា និងជាអ្នកមានគ្រប់លក្ខណសម្បត្តិតាមគោលការណ៍កំណត់ ។

២-ត្រូវពិនិត្យរៀបចំបន្ថែមមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ជាសមាជិកបក្សថ្មី ដែលស្ថិតនៅលំដាប់លេខរៀងទី១មកពីគណបក្សបក្សផ្សេងដែលសុំចូលរួមជីវភាពជាមួយគណបក្សប្រជាជនកម្ពុជា អោយទទួលជាអនុប្រធាន ឬសមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សឃុំ សង្កាត់។ ចំពោះជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ផ្សេងទៀត អាចពិនិត្យរៀបចំបន្ថែម ជាសមាជិកគណៈអចិន្ត្រៃយ៍ឬសមាជិកគណៈកម្មាធិការគណបក្សឃុំ សង្កាត់ ស្របតាមសំណូមពរភារកិច្ចជាក់ស្តែង ។

៣-ត្រូវយកចិត្តទុកដាក់ពង្រឹងសាមគ្គីភាព ឯកភាពផ្ទៃក្នុង និងអប់រំបំពាក់បំប៉នដល់សមាជិកបក្សថ្មី ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មកពីគណបក្សផ្សេងដែលសុំចូលរួមជីវភាពជាមួយគណបក្សប្រជាជនកម្ពុជាដើម្បីលើកកម្ពស់ការយល់ដឹង និងខិតខំប្រតិបត្តិអោយបានត្រឹមត្រូវតាមកម្មវិធីនយោបាយ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងគោលការណ៍ សេចក្ដីសម្រេចនានារបស់គណបក្ស ។

ខុទ្ទកាល័យ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្ដាល ស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មានភារកិច្ច ចាត់តាំងអនុវត្តសេចក្ដីណែនាំនេះ ។

**ជ.គណៈអចិន្ត្រៃយ៍**
**ប្រធាន**

**ហ៊ុន សែន**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខ : ០០១/០៦២១/សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃ ពុធ ៧រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ២០២១

# សេចក្តីណែនាំបន្ថែម
# ស្តីពីរចនាសម្ព័ន្ធស្នាក់ការគណបក្សឃុំ សង្កាត់

**យោង** : - សេចក្តីណែនាំលេខ ៧៩ សណ.គក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០២
- សេចក្តីកំណត់លេខ ២២ សណ.គក ចុះថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ១៩៩៥
- សំណូមពរនៃការងារគណបក្សក្នុងដំណាក់កាលបច្ចុប្បន្ន
- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០២១

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល** ណែនាំបន្ថែមអំពីការរៀបចំរចនាសម្ព័ន្ធស្នាក់ការគណបក្សឃុំ សង្កាត់ ដូចខាងក្រោម :

១. ស្នាក់ការគណបក្សឃុំ សង្កាត់ ត្រូវមានប្រធាន ១រូប និងមន្ត្រីជំនួយការ ២រូប ទទួលបន្ទុកប្រចាំការរបស់គណៈកម្មាធិការគណបក្សឃុំ សង្កាត់ ដើម្បីដោះស្រាយការងារគណបក្ស និងទទួលជួបទំនាក់ទំនងជាមួយមន្ត្រី សមាជិកគណបក្ស និងមហាជនប្រជាជននៅមូលដ្ឋាន ។

២. ប្រធានស្នាក់ការគណបក្សឃុំ សង្កាត់ ត្រូវជ្រើសរើសតែងតាំងក្នុងចំណោមប្រធាន ឬអនុប្រធានគណៈកម្មាធិការគណបក្ស ដែលពុំមែនជាមេឃុំ ចៅសង្កាត់ ។

៣. មន្ត្រីជំនួយការស្នាក់ការគណបក្សឃុំ សង្កាត់ ២រូប ត្រូវជ្រើសរើសតែងតាំងក្នុងចំណោមសមាជិកគណៈកម្មាធិការគណបក្សឃុំ សង្កាត់ ។

ខុទ្ទកាល័យ និងគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំនេះ ។

**ជ.គណៈអចិន្ត្រៃយ៍**
**អនុប្រធាន**

**សាយ ឈុំ**